

# របាយការណ៍ប្រចាំឆ្នាំ ២០១៨

*លទ្ធផលសម្រេចបានសំខាន់ៗ*

ជីវិតធម្មជាតិនៅកម្ពុជា

NatureLife Cambodia



# មាតិកា


១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម ............................ ១

២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០១៨ ............................................ ២

២.១ ទប់ស្កាត់ការផុតពូជ ២

២.២ អភិរក្សទីជម្រក ៤

២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ ៥

២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ៦

២.៥ កសាងសមត្ថភាព ៩

៣. របាយការណ៍ហិរញ្ញវត្ថុ ............................................................ ១២

៤. ដៃគូ និងម្ចាស់ជំនួយ ............................................................ ១៣




# ១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម

អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការក្នុងស្រុកខាងផ្នែកអភិរក្សដែលបានចុះបញ្ជីជាផ្លូវការក្នុងក្រសួងមហាផ្ទៃក្នុងខែកុម្ភៈ ឆ្នាំ២០១៧។ អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការដែលមិនស្វែងរកប្រាក់កម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ និងមិនផ្តល់មធ្យោបាយជាសម្ភារហិរញ្ញវត្ថុ ឬធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬមនោគមវិជ្ជាណាមួយឡើយ។ អង្គការនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការជីវិតសត្វស្លាបអន្តរជាតិ ( BirdLife International ) ក្រោមជំនួយផ្នែកហិរញ្ញវត្ថុពី មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង (CEPF) តាមរយៈអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)។ អង្គការជីវិតធម្មជាតិនៅកម្ពុជា ត្រូវបានបង្កើតឡើងដោយស្ថាបនិក១២នាក់ ដែលក្នុងនោះ១០នាក់ គឺជាបុគ្គលិកស្នូលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំកម្ពុជា។ ការផ្តួចផ្តើមបង្កើតឡើងនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអន្តរកាលនៃការកសាងសមត្ថភាពអង្គការក្នុងស្រុករបស់អង្គការជីវិតសត្វស្លាបអន្តរជាតិដើម្បីអាចចាប់ជាដៃគូនាពេលអនាគត (គិតមកដល់បច្ចុប្បន្នអង្គការជីវិតសត្វស្លាបអន្តរជាតិមានដៃគូចំនួន ១២១ ក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក)។ បន្ទាប់ពីការបង្កើតកម្មវិធីដោយផ្ទាល់នៅក្នុងវិស័យអភិរក្ស និងការកសាងសមត្ថភាពដល់អ្នកអភិរក្ស និងបុគ្គលិកក្នុងស្រុកអស់រយៈពេលជាង១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា អង្គការជីវិតសត្វស្លាបអន្តរជាតិកំពុងតែរៀបចំយុទ្ធសាស្ត្រជ្រើសរើសដៃគូក្នុងប្រទេសកម្ពុជា ។ សមាជិកស្ថាបនិកទាំង ១២ នាក់របស់អង្គការជិវិតធម្មជាតិកម្ពុជា ជឿជាក់យ៉ាងមុតមាំថាបុគ្គលិកកម្ពុជានឹងអាចអនុវត្តបេសកកម្មរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិនេះបានដោយរលូន។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអង្គការជីវិតធម្មជាតិនៅកម្ពុជា លើកទីមួយ*

ស្ថាបនិកអង្គការជីវិតធម្មជាតិនៅ កម្ពុជាជឿជាក់ថាយើងនឹងអាចបន្តការងារអភិរក្សរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិក្នុងនាមជាអង្គការដៃគូរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិនៅប្រទេសកម្ពុជា។ ដោយការស្រលាញ់ធម្មជាតិ និងមនុស្សយើងជឿជាក់ថានិរន្តរភាពគឺកើតមាននាពេលអនាគត។

- **ចក្ខុវិស័យ៖ ទាំងអស់គ្នាដើម្បីរស់នៅប្រកបដោយសុខដុមរមនារវាងមនុស្ស និងធម្មជាតិ។**
- **បេសកកម្ម៖ធ្វើការអភិរក្សជីវចម្រុះតាមរយៈការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពដើម្បីជាប្រយោជន៍របស់យើងទាំងអស់គ្នា។**

និងបែងចែកជាកម្មវិធី៥៖

១. ទប់ស្កាត់ការផុតពូជ ២. អភិរក្សទីជម្រក ៣. អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

៤. លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ៥. កសាងសមត្ថភាព

# ២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០១៨

## ២.១ ទប់ស្កាត់ការផុតពូជ

- ចូលរួមការពារ និងអភិរក្សសត្វត្មាតកម្ពុជា ដោយសហការជាមួយក្រុមការងារអភិរក្សសត្វត្មាតកម្ពុជារៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសត្វត្មាតនៅកម្ពុជា នៅផ្សារទំនើបអ៊ីអនភ្នំពេញ ដោយមានការដាក់តាំងរូបភាពសត្វត្មាត និងសកម្មភាពអភិរក្សសត្វត្មាត ការគូសគំនូ សំនួរចម្លើយ ចំរៀង និងសន្ទរកថាពីវាគ្មិន ដើម្បីផ្សព្វផ្សាយ និងទាក់ទាញចំណាប់អារម្មណ៍ពីមហាជនក្នុងការអភិរក្ស និងចូលរួមទប់ស្កាត់ការផុតពូជរបស់សត្វត្មាតពីកម្ពុជា។




*សកម្មភាពលើកកម្ពស់ការយល់ដឹងអំពីសត្វត្មាតនៅកម្ពុជា*




*សកម្មភាពលើកកម្ពស់ការយល់ដឹងអំពីសត្វត្មាតនៅកម្ពុជា*




*ក្រុមការងារមួយផ្នែកក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសត្វត្មាតនៅកម្ពុជា*

- រៀបចំសកម្មភាពផ្សព្វផ្សាយអំពីសត្វក្រៀល នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ ដោយមានធ្វើបទបង្ហាញអំពីជីវសាស្ត្រសត្វក្រៀល និងការងារអភិរក្ស ដល់សិស្សានុសិស្ស និងរៀបចំការចុះកម្មសិក្សាដល់សិស្ស ទៅតំបន់ដីសើម និងមើលសត្វក្រៀល។ ការបណ្តុះគំនិតស្រលាញ់សត្វក្រៀល និងធម្មជាតិដល់សិស្សានុសិស្សនៅជុំវិញតំបន់ដីសើមដែលជាទីជម្រកសត្វក្រៀល គឺជួយការកាត់បន្ថយសកម្មភាពដែលប៉ះពាល់ដល់សត្វក្រៀលដោយ។




*សកម្មភាពក្នុងការផ្សព្វផ្សាយអភិរក្សសត្វក្រៀល នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ*

## ២.២ អភិរក្សទីជម្រក

- ចូលរួមក្នុងការងារការដាក់បញ្ចូលតំបន់ស្ទួលស្ទឹងសែន និងតំបន់ជុំវិញជាតំបន់រ៉ាមសារស្ទឹងសែន ដែលដឹកនាំការដាក់បញ្ចូលដោយនាយដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប ក្រសួងបរិស្ថាន សហការជាមួយអង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីប្រចាំកម្ពុជា។



*សិក្ខាសាលាថ្នាក់ជាតិស្តីពីការដាក់បញ្ចូលតំបន់ស្ទួលស្ទឹងសែន និងតំបន់ជុំវិញជាតំបន់រ៉ាមសារស្ទឹងសែន*




*តំឡើងផ្ទាំងពត៌មានអំពីតំបន់រ៉ាមសារស្ទឹងសែន នៅខេត្តកំពង់ធំ*

## ២.៣ អភិរក្សសត្វស្លាបទេសន្តប្រវេសន៍

- ការសិក្សាស្រាវជ្រាវពីសត្វស្លាបទេសន្តប្រវេសន៍ នៅតំបន់វ៉ាមសារកោះកាពិ ខេត្តកោះកុង ដែលយើងបានឃើញមានសត្វស្លាបទេសន្តប្រវេសន៍ប្រមាណជាង ២០ ប្រភេទ ចំនួនជាង ២០០០ ក្បាល។ យើងបានឃើញមានសត្វរំពេតូចធ្វើសំបុកជាក្រុមនៅលើវាលខ្សាច់។



*សកម្មភាពចុះសិក្សាសត្វស្លាបទេសន្តប្រវេសន៍ នៅតំបន់វ៉ាមសារកោះកាពិ*



*សត្វស្លាបទេសន្តប្រវេសន៍ នៅតំបន់វ៉ាមសារកោះកាពិ*

- ការចូលរួមរៀបចំទិវាសត្វស្លាបទេសន្តរប្រវេសន៍ឆ្នាំ ២០១៨ ក្រោមប្រធានបទ រួមគ្នាក្នុងការអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ នៅតំបន់ការពារទេសភាពអន្លង់ព្រីង ខេត្តកំពត និងតំបន់ការពារទេសភាពអាងត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ។



*សកម្មភាពក្នុងទិវាសត្វស្លាបទេសន្តរប្រវេសន៍ឆ្នាំ ២០១៨ នៅតំបន់ការពារទេសភាពអន្លង់ព្រីង*

## ២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន

- ចូលរួមរៀបចំកម្មវិធីទិវាតំបន់ដីសើមពិភពលោកឆ្នាំ ២០១៨ ក្រោមប្រធានបទ តំបន់ដីសើមជាយក្រុង ដែលចូលរួមក្នុងការលើកម្ពស់ការយល់ដឹង និងចូលរួមការអភិរក្សតំបន់ដីសើមពីសហគមន៍មូលដ្ឋាន។
- បញ្ជ្រាបការយល់ដឹងអំពីសត្វស្លាប និងជីវចម្រុះតាមបណ្តាញសង្គម ដោយធ្វើការបង្ហោះរូបភាព ឬចែករំលែកពត៌មានអំពីសត្វស្លាបដែលមានវត្តមាននៅប្រទេស នៅចំនេះដឹងដែលទាក់ទងនឹងសត្វស្លាប ដល់សាធារណៈជនក្នុងគោលបំណងបណ្តុះការស្រលាញ់សត្វស្លាប និងធម្មជាតិ ហើយចាប់ផ្តើមចូលរួមការអភិរក្ស។
- ការចូលរួមរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ដោយមានការតំឡើងផ្ទាំងពត៌មាន និងបទបង្ហាញដល់សិស្សានុសិស្ស និងសហគមន៍មូលដ្ឋាន។
- រៀបចំពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១ ដោយសហការជាមួយក្រសួងបរិស្ថាន និងអង្គការដៃគូ។ ពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១ គឺប្រារព្ធឡើងនៅវត្តភ្នំ ដោយមានការចូលរួមពីអង្គការអភិរក្សសត្វស្លាបពីបណ្តាប្រទេសនៅអាស៊ី សាធារណៈជន សិស្សានុសិស្ស និងអ្នកដែលមកទេសនានៅវត្តភ្នំ សរុបប្រមាណជាង ៣០០០ នាក់។ កម្មវិធីនេះបានរៀបចំឡើងក្នុងរយៈពេល ២ ថ្ងៃ ដោយមានសកម្មភាពការមើលសត្វ ការតាំងរូបភាពសត្វស្លាប ការគូរគំនូរសត្វស្លាប ការតាំងស្តង់ បទបង្ហាញទាក់ទងនឹងការងារអភិរក្សសត្វស្លាប និងទេសចរណ៍ធម្មជាតិនៅកម្ពុជា។



*ពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១*




*សកម្មភាពក្នុងពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១*



*ការតាំងរូបភាពសត្វស្លាបក្នុងពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១*




*អ្នកចូលរួមតាំងពិព័រណ៍ក្នុងពិព័រណ៍សត្វស្លាបកម្ពុជាលើកទី១*



*សកម្មភាពការមើលសត្វក្នុងទិវាតំបន់ដីសើមពិភពលោកឆ្នាំ ២០១៨*



*ការតំឡើងផ្ទាំងពត៌មានអំពីសត្វក្រៀល នៅតំបន់ការពារទេសភាពអាងត្រពាំងថ្ម*

## ២.៥ កសាងសមត្ថភាព

- រៀបចំផែនការយុទ្ធសាស្ត្រកម្មវិធី ១០ ឆ្នាំ ដែលជាឯកសារតម្រង់ទិសកម្មវិធីរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជា
- រៀបចំផែនការស្វែងរកជំនួយ ដែលជាឯកសារតម្រង់ទិសរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជា
- ចូលរួមពិព័រណ៍សត្វស្លាបអាស៊ី និងពិព័រណ៍សត្វស្លាបថៃ ក្នុងការសិក្សាបទពិសោធន៍ក្នុងការរៀបចំកម្មវិធី ចែករំលែកបទពិសោធន៍ និងបង្កើនទំនាក់ទំនងក្នុងបណ្តាសមាគមន៍សត្វស្លាបជុំវិញពិភពលោក។

- ចូលរួមកិច្ចប្រជុំដៃគូ នៃបណ្ដាញផ្លូវហោះហើរសត្វស្លាបទេសន្តរប្រវេសន៍ អាស៊ីខាងកើត អូស្ត្រាលី លើកទី១០ នៅប្រទេសចិន ដើម្បីការសិក្សាបទពិសោធន៍ ចែករំលែកបទពិសោធន៍ និងបង្កើនទំនាក់ទំនង។




*ស្តង់ក្នុងអង្គការជីវិតធម្មជាតិនៅកម្ពុជាក្នុងពិព័រណ៍សត្វស្លាបថៃ*




*ការចែករំលែកបទពិសោធន៍ និងទេសចរណ៍ធម្មជាតិ នៅកម្ពុជា*




*ចូលរួមកិច្ចប្រជុំដៃគូបណ្តាញផ្លូវហោះហើរសត្វស្លាបទេសន្តរប្រវេសន៍អាស៊ីខាងកើត អូស្ត្រាលី លើកទី១០*




*ការសិក្សាពីបទពិសោធន៍ក្នុងការរៀបចំពិព័រណ៍សត្វស្លាប*

# ៣. របាយការណ៍ហិរញ្ញវត្ថុ

**របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨**

| | 2018 US$ |
|---|---|
| **ចំណូល** | |
| ចំណូលទទួលបានពីម្ចាស់ជំនួយ | 29314.00 |
| វិភាគទានពីម្ចាស់ជំនួយឯកជន | 2054.33 |
| ចំណូលផ្សេងៗ | 709.00 |
| | **32077.33** |
| **ចំណាយ** | |
| ចំណាយលើបុគ្គលិក | 1713.68 |
| សម្ភារៈការិយាល័យ / សម្ភារៈ / ឧបករណ៍ប្រើប្រាស់ | 69.15 |
| ទូរគមនាគមន៍ / ប៉ុស្តិ៍ / អ៊ិនធឺណិត | 42.00 |
| ការងារអភិរក្ស និងសហគមន៍ | 20479.89 |
| សិក្ខាសាលា / កិច្ចប្រជុំ | 4902.38 |
| ឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ | 561.80 |
| ការធ្វើដំណើរ | 281.98 |
| ចំណាយប្រយោល | 21.33 |
| | **28072.21** |
| **ការទូទាត់ចំណូល និងចំណាយ** | **4005.12** |
| **សមតុល្យពីឆ្នាំមុន** | **314.86** |
| **សមតុល្យបំណាច់ឆ្នាំ២០១៨** | **4319.98** |

# ៤. ដៃគូ និងម្ចាស់ជំនួយ

## ស្ថាប័នរដ្ឋ

## អង្គការដៃគូ និងក្រុមការងារ

## ម្ចាស់ជំនួយ

Rob & Jos Donation




**អង្គការជីវិតធម្មជាតិនៅកម្ពុជា**
រតនគិរី៖ ផ្ទះលេខ៣៥ ផ្លូវលេខ៣៣ ភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
ភ្នំពេញ៖ ផ្ទះលេខ៣២A សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល៖ admin@naturelifecambodia.org
គេហទំព័រ ៖ www.naturelifecambodia.org
លេខទំនាក់ទំនង៖ ០៧៨ ៧៣២ ២៤០ ឬ ០២៣ ៩៩៣ ៦៣១